3/14

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រៃវែង

សំណុំរឿងរដ្ឋប្បវេណី

លេខ ១២៤ ចុះថ្ងៃទី ០៣

ខែ សីហា ឆ្នាំ ២០១២

**សាលក្រម**

លេខ ០៦ (ក) រ.វ

ចុះថ្ងៃទី ២០ ខែ កុម្ភៈ

ឆ្នាំ ២០១៣

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តព្រៃវែង**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ប្រកាសសាលក្រមថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដោយមានសមាសភាពដូចខាងក្រោម :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានសាលាដំបូងខេត្តព្រៃវែង

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង

**មេធាវីតំណាងដោយអាណត្តិអោយដើមចោទ**

លោកស្រី [redacted]

សំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី ០៣.៨.២០១២

រវាងដើមចោទឈ្មោះ [redacted] **ឈួន** ភេទ ប្រុស អាយុ ៤៨ ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ឪពុកឈ្មោះ [redacted] **ប្រុក** (រ) ម្តាយឈ្មោះ [redacted] **អួន** (ស) ប្រពន្ធឈ្មោះ [redacted] **ខេន** ។

និងចុងចំលើយឈ្មោះ [redacted] **សារ៉េត** ភេទ ប្រុស អាយុ ៤៨ ឆ្នាំ ជាតិខ្មែរ មុខរបរ នគរបាលស្រុក បុទុមសាគរ ទីលំនៅភូមិ អណ្តូងទឹក ឃុំ អណ្តូងទឹក ស្រុក បុទុមសាគរ ខេត្ត កោះកុង ឪពុកឈ្មោះ [redacted] **ហាំ** (ស) ម្តាយឈ្មោះ [redacted] **ហោ** (រ) ប្រពន្ធឈ្មោះ [redacted] **សុខឿន** ។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារសុំអោយតុលាការចេញសាលក្រមដូចខាងក្រោម :

- ទាមទារដីភូមិទំហំ ២០ ម គុណ ១០០ ម មានទីតាំងនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

-ទាមទារដីចំការទំហំ ២០ ម គុណ ៣០០ ម មានទីតាំងស្ថិតនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

២៦៧



Scanned with CamScanner

-ទាមទារដីស្រែប្រាំងទំហំ ២១ ម គុណ ២៧០ ម មានទីតាំងនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

-និងទាមទារដីចំការទំហំ ៨ ម គុណ ៧០០ ម មានទីតាំងនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

**ចុងចំលើយប្តឹងតប** : សុំទាមទារដីដូចខាងក្រោម

**-ទី ១** ដីប្រាំងមានទំហំ ១៩.៥០ ម គុណ ៤០០ ម មានព្រំប្រទល់

-ខាងកើតទល់ទទឹក

-ខាងលិចទល់នឹងដីឈ្មោះ [redacted] **ហោ**

-ខាងជើងទល់ដីឈ្មោះ [redacted] **យ៉ាន់**

-ខាងត្បូងទល់ដីឈ្មោះ [redacted] **សាឯម**

**-ទី ២** ដីចំការ( ដីឡូត៍ ) មានទំហំ ៨ ម គុណ ៧០០ ម មានព្រំប្រទល់

-ខាងកើតទល់នឹងផ្លូវរទេះ

-ខាងលិចទល់នឹងផ្លូវរទេះ

-ខាងជើងទល់នឹងដីឈ្មោះ [redacted] **សន**

-ខាងត្បូងទល់ដីឈ្មោះ [redacted] **សាឯម**

**-ទី ៣** ដីភូមិ+ចំការមានទំហំ ២០ ម គុណ ៥០០ ម មានព្រំប្រទល់

-ខាងកើតទល់នឹងទន្លេ

-ខាងលិចទល់ដីប្រាំង

-ខាងជើងទល់ដីឈ្មោះ [redacted] **ថាវី**

-ខាងត្បូងទល់ដីឈ្មោះ [redacted] **ហួយ**

ដីទាំងបីកន្លែងស្ថិតនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

១-**អង្គហេតុ និង ចំណុចវិវាទ**

ក-**អង្គហេតុ**

-ដើមចោទនិងប្រពន្ធបានអះអាងថាខ្លួនបានរស់នៅលើដីភូមិ ដីធ្វើចំការ និង ដីប្រាំង ដែលមានទីតាំង និងទំហំដូចមានក្នុងកម្មវត្ថុបណ្តឹង តាំងពីឆ្នាំ ១៩៨៤ មកម្លេះពុំដែលមានទំនាស់ និង ពុំមាននរណា មកអះអាងដីទាំងនេះជារបស់អ្នកណាទេ គឺរស់នៅលើដីភូមិ និង ធ្វើស្រែចំការតរៀង១មក ទើបតែនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ មានសេចក្តីជូនដំណឹងរបស់លោកមេឃុំស្តីពីឈ្មោះ [redacted] **ហួន** បាមជូនដំណឹងដល់ដើមចោទ



Scanned with CamScanner

អោយចុះរើ និង សែងផ្ទះចេញពីដីរបស់ឈ្មោះ [redacted] **សារ៉េត** និង ប្រពន្ធឈ្មោះ [redacted] **សុខឿន** (ចុងចំលើយ) ចាប់ពីថ្ងៃទី ១០.៧.២០១២ ជាកំណត់ដើម្បីអោយ ម្ចាស់កម្មសិទ្ធិ (ចុងចំលើយ ) ចូលមកគ្រប់គ្រងលើទ្រព្យសម្បត្តិខាងលើ ។

-ចុងចំលើយបានអះអាងថា ចំពោះការទាមទារដីខាងលើរបស់ដើមចោទ ចុងចំលើយមិនឯកភាពទេ ដោយមូលហេតុចុងចំលើយបានទទួលដីទាំងនេះពីឪពុកម្តាយ ដោយកាលណោះ ឪពុកម្តាយបានចែកដីទាំងនេះជាពីរចំណែក មួយចំណែកអោយទៅចុងចំលើយ និង មួយចំណែកទៀតអោយប្អូន ឈ្មោះ [redacted] **ភ័ស** ហើយ ក្រោយមកប្អូន ឈ្មោះ [redacted] **ភ័ស** ក៏បានលក់មកអោយចុងចំលើយ ហើយការរស់នៅរបស់ដើមចោទមកទល់សព្វថ្ងៃនេះ គឺ គ្រាន់តែបណ្តោះអាសន្នប៉ុណ្ណោះ ចុងចំលើយបានអះអាងថាខ្លួនមានឯកសារគ្រប់គ្រាន់ ។

ខ-**ចំណុចវិវាទ**

-ដើមចោទនៅតែទាមទារដីភូមិ ដីស្រែ និង ដីចំការ ដូចក្នុងកម្មវត្ថុខាងលើ ។

-ចុងចំលើយក៏ទាមទារសុំអោយតុលាការចេញសាលក្រមប្រគល់ដីទំនាស់មកអោយខ្លួនកាន់កាប់វិញ ។

២-**អំពីភស្តុតាងរបស់គូភាគី**

ក-**ភស្តុតាងរបស់ដើមចោទ**

**ភស្តុតាងជាឯកសាររបស់ដើមចោទ**

-លិខិតបំភ្លឺ

-សៀវភៅគ្រួសារ

-លិខិតបញ្ជាក់របស់ប៉ុស្តិ៍នគរបាលអង្គរអង្គ

-លិខិតបំភ្លឺចុះថ្ងៃទី ០២.៨.២០១២

-លិខិតបញ្ជាក់របស់លោកមេឃុំអង្គរអង្គចុះថ្ងៃទី ៩.២.២០១៣

- **ភស្តុតាងជាសាក្សីរបស់ដើមចោទ**

១-ឈ្មោះ [redacted] **សុខ**

២-ឈ្មោះ [redacted] **ភឿង**

៣-ឈ្មោះ [redacted] **សារី**

ខ-**ភស្តុតាងរបស់ចុងចំលើយ**

-**ភស្តុតាងជាសាក្សីរបស់ចុងចំលើយ**

១-ឈ្មោះ [redacted] **សារ៉េត**

២-ឈ្មោះ [redacted] ភ័ស

៣-ឈ្មោះ [redacted] ស៊ន់

-**ភស្តុតាងជាឯកសាររបស់ចុងចំលើយ**

១-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] **ស៊ាន** អោយទៅឈ្មោះ [redacted] **ភស័** និង ឈ្មោះ [redacted] **ខឿន** ចំនួន ០៣ ច្បាប់ ។

២-លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] **ភ័ស** អោយទៅ ឈ្មោះ [redacted] **សារ៉េត** និង ឈ្មោះ [redacted] **ខឿន** ចំនួន ០៣ ច្បាប់ ។

៣-សំណើរស្នើសុំលិខិតកាន់កាប់ដីធ្លី ចុះថ្ងៃទី ១៣.៨.២០០៧ របស់ឈ្មោះ [redacted] **សារ៉េត** និង ឈ្មោះ [redacted] **ខឿន** ចំនួន ០៤ ច្បាប់ ។

៤-កំណត់ហេតុស្តីពីដំណោះដោះស្រាយដីធ្លីរវាងដើមបណ្តឹង [redacted] **សារ៉េត** និង ចុងបណ្តឹង [redacted] ខេន ចុះថ្ងៃទី ០៩.៨.២០១១ ចំនួន ០១ ច្បាប់ ។

៥-កិច្ចសន្យាចុះថ្ងៃទី ០៩.៨.២០១១ ចំនួន ០១ ច្បាប់ ។

៦-លក្ខ័ណព្រមព្រៀងរបស់ឈ្មោះ [redacted] **ខេន** និង ប្តីឈ្មោះ [redacted] **ឈួន** ចុះថ្ងៃទី ០៩.៨.២០១១ ចំនួន ០១ ច្បាប់ ។

៧-លិខិតប្រគល់ ចុះថ្ងៃទី ០៩.៨.២០១១ ចំនួន ០១ ច្បាប់ ។

៨-កិច្ចសន្យាជួលដី ចុះថ្ងៃទី ១៩.៧.២០០៧ ចំនួន ០១ ច្បាប់ ។

៩-លិខិតទិញ លក់ ចុះថ្ងៃទី ០១.៨.២០១២ ចំនួន ០១ ច្បាប់ ។

១០-គំនូសប្លង់កន្លែងដីទំនាស់ ចំនួន ០១ ច្បាប់ ។

១១-ពាក្យបណ្តឹងចុះថ្ងៃទី ០២.៨.២០១២ ។

១២-របាយរកាណ៍សកម្មភាពចុះថ្ងៃទី ០៣.៨.២០១១ ។

១៣-សេចក្តីជូនដំណឹងចុះថ្ងៃទី ១៩.៨.២០១១

១៤-ដីកាអមលេខ ០០៧ ចុះថ្ងៃទី ០២.៨.២០១២

១៥-បង្កាន់ដៃអង្កេតវាស់វែងដីធ្លី ចុះថ្ងៃទី ២៩.៣.១៩៩២

**<u>សេចក្តីថ្លែងការណ៍របស់គូភាគី</u>**

ក-**សេចក្តីថ្លែងការណ៍របស់ដើមចោទ**

ដើមចោទឈ្មោះ [redacted] **ឈួន** បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្ញុំបាទសុំទាមទារសុំអោយតុលាការចេញសាលក្រមដូចខាងក្រោម :

-ទាមទារដីភូមិទំហំ ២០ ម គុណ ១០០ ម មានទីតាំងនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

-ទាមទារដីចំការទំហំ ២០ ម គុណ ៣០០ ម មានទីតាំងស្ថិតនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

-ទាមទារដីស្រែប្រាំងទំហំ ២១ ម គុណ ២៧០ ម មានទីតាំងនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

-និងទាមទារដីចំការទំហំ ៨ ម គុណ ៧០០ ម មានទីតាំងនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

**មូលហេតុ** : ខ្ញុំបាទ និង ប្រពន្ធរស់នៅពីលើដីភូមិ ដីធ្វើស្រែចំការ និង ដីប្រាំង ដែលមានទីតាំង និង ទំហំ ដូចមានក្នុងកម្មវត្ថុបណ្តឹង តាំងពីឆ្នាំ ១៩៨៤ មកម្លេះ ពុំដែលមានទំនាស់ និង មាននរណាមកអះអាងលើដីនោះទេ គឺ ចេះតែរស់នៅលើដីភូមិ និង ធ្វើស្រែចំការត១រៀងមក ។ ទើបតែនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ មានសេចក្តីជូនដំណឹងរបស់លោកមេភូមិអង្គរអង្គ ស្តីពីឈ្មោះ [redacted] **ហួន** បានជូនដំណឹងមកខ្ញុំបាទ និង ប្រពន្ធ អោយរុះរើ ឬ សែងផ្ទះ ចេញពីដីភូមិរបស់លោក [redacted] **សាវ៉េត** និង ប្រពន្ធឈ្មោះ [redacted] **សុខឿន** (ចុងចំលើយ ) ចាប់ពីថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២ ជាកំណត់ ដើម្បីអោយម្ចាស់កម្មសិទ្ធិចូលមកគ្រប់គ្រងលើទ្រព្យសម្បត្តិ និង ចំពោះដើមឈើ ក៏ ត្រូវគាស់ កាប់ចេញផង ។

-ឪពុកម្តាយរបស់ខ្ញុំបានចំណាកស្រុកនៅរស់ជាមួយកូននៅខេត្ត កោះកុងក្នុងឆ្នាំ ២០០០ ក្រោយពីនៅខេត្តកោះកុងឪពុកពុំធ្លាប់មកស្រុកទេ ប៉ុន្តែម្តាយគាត់ធ្លាប់មកលេងរយះពេល ៣ ទៅ ៤ ខែ មកលេងស្រុកម្តង។

-ដីនេះរដ្ឋអំណាចជាអ្នកចែកឱ្យ កាលណោះឪពុកម្តាយជាមេគ្រួសារ ខ្ញុំបាទគ្រាន់តែជាអ្នករស់នៅជាមួយ ហើយនៅឆ្នាំ ២០០៧ ឪពុកម្តាយក៏មកស្រុកហើយបានធ្វើលិខិតសិទ្ធិកាន់កាប់ដីទាំងអស់នេះឱ្យទៅឈ្មោះ [redacted] **សុខឿន** និង ឈ្មោះ [redacted] **ភ័ស** ប៉ុន្តែខ្ញុំបាទពុំបានយល់ព្រមទេ ហើយខ្ញុំក៏ពុំបានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិនោះដែរ ។

-ខ្ញុំបាទធ្លាប់បានទទួលដីដែលរដ្ឋអំណាចចែកឱ្យមួយកន្លែងនៅឆ្នាំ ១៩៨៤ នៅចំណុចបត់ត្រង់ទំហំ ២០ ម គុណ ២០០ ម ក្នុងភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ដល់ឆ្នាំ ១៩៨៨ ខ្ញុំបាននៅរស់នៅចំណុចបត់ត្រង់នោះបានប្រហែល ១ ឆ្នាំ ហើយខ្ញុំក៏លក់ដីនេះទៅ ហើយមករស់នៅលើដីសព្វថ្ងៃនេះរហូតមក ។

**សំណូមពរ** សុំទាមទារដីទាំង ៤ កន្លែងដដែល ។



Scanned with CamScanner

35/9

## ខ-សេចក្ដីថ្លែងការណ៍របស់ចុងចំលើយ

ចុងចំលើយឈ្មោះ [redacted] **សារ៉េត** បានថ្លែងការណ៍

-ឆ្នាំ ១៩៨៤ ឈ្មោះ [redacted] **ឈួន** ប្រពន្ធឈ្មោះ [redacted] **ខេន** ពិតជារស់នៅលើភូមិនេះមែន តែរស់នៅជុំគ្នាជាមួយឪពុកម្ដាយបងប្អូនទាំងអស់ ។

-ឆ្នាំ ១៩៨៦ ឈ្មោះ [redacted] **ឈួន** ប្រពន្ធ ឈ្មោះ [redacted] **ខេន** បានទៅរស់នៅលើដីរបស់គាត់ ឯបត់ត្រង់ដែលជាដីរបស់រដ្ឋអំណាចចែកឱ្យ អស់រយៈពេល ៣ ឆ្នាំ ក្រោយមកគាត់ក៏លក់ដីគាត់ចោលអស់ ហើយក៏មកសុំស្នាក់នៅលើផ្ទះ លើដីភូមិរបស់ខ្ញុំបាទសព្វថ្ងៃនេះ តែដោយយល់ឃើញថាបងចេះតែឱ្យគាត់រស់នៅបណ្ដោះអាសន្នទៅ ។

-ក្នុងឆ្នាំ ១៩៩៩ ខ្ញុំបាទ ឈ្មោះ [redacted] **សារ៉េត** ប្រពន្ធឈ្មោះ [redacted] **ខឿន** បានទៅចាក់ជើងសសរចំនួន ១៥ ដើមជាប់នៅលើដីភូមិនោះ ទុកអស់រយៈពេលជាងមួយឆ្នាំ ដោយគ្រួសារមានធុរៈមិនបានធ្វើផ្ទះ ក៏ លក់សរសរតាំងនោះអស់ទៅ ។

-ចន្លោះឆ្នាំ ១៩៩៨ ទៅ ២០០០ ពុក ម៉ែ ឈ្មោះ [redacted] **ស៊ាន** ប្រពន្ធ ឈ្មោះ [redacted] **អ៊ុន** គាត់ក៏សំរេចចិត្តចុះចេញពីផ្ទះនេះ ហើយធ្វើកូនផ្ទះតូចមួយនៅចំពីមុខផ្ទះសព្វថ្ងៃនេះ ពីរអ្នកយាយតា ។

ក្រោយមកគាត់ក៏ត្រឡប់ទៅលេងកូនឯកោះកុង គាត់ទៅមកជារៀងរាល់ឆ្នាំ ឱ្យតែដល់ខែធ្វើរបរ ។

ឈ្លៀតឱកាស **ពុក ម៉ែ** ទៅកោះកុង កូនឈ្មោះ [redacted] **ឈួន** ប្រពន្ធឈ្មោះ [redacted] **ខេន** ក៏រុះកូនផ្ទះគាត់ចោលទៀត ។

-ចុងឆ្នាំ ២០០៤ ម្ដាយឈ្មោះ [redacted] **អ៊ុន** ត្រឡប់មកស្រុកវិញ ពេលនោះកូន ឈ្មោះ [redacted] **ឈួន** ប្រពន្ធឈ្មោះ [redacted] **ខេន** បានលួងលោមម្ដាយឱ្យគាត់ផ្ដិតមេដៃលក់ដី ១០ ម គុណ ៤០ ម ខាងកើតផ្លូវឱ្យទៅឈ្មោះ [redacted] **ភីរះ** ប្រពន្ធឈ្មោះ [redacted] **នាង** ដោយលក់ពីខ្ញុំ និង ប្រពន្ធខ្ញុំមិនឱ្យដឹង ក្រោយពីឈ្មោះ [redacted] **ភីរះ** ប្រពន្ធឈ្មោះ [redacted] **នាង** ទិញដីបានហើយ គេក៏សងផ្ទះគ្បឿងពីរខ្នងរស់នៅជិតគ្នាមិនបានប៉ុន្មានខែផង គ្រួសារ [redacted] **ភីរះ** និង គ្រួសារ [redacted] **ឈួន** ក៏ ឈ្លោះប្រកែកគ្នា រហូតដល់វាយតប់គ្នាផង ពេលនោះឈ្មោះ [redacted] **ឈួន** ប្រពន្ធឈ្មោះ [redacted] **ខេន** ក៏ចាប់ផ្ដើមដេញគេចេញពីដី តែភាគីម្ខាងគេមិនចេញ គេឆ្លើយមកវិញថា អ្នកឯងមិនមែនម្ចាស់ទេ កុំមកចេះតែដេញគេ ក្រោយពីដេញគេមិនចេញ ឈ្មោះ [redacted] **ឈួន** និង ប្រពន្ធឈ្មោះ [redacted] **ខេន** ក៏តែប្រាប់ខ្ញុំដោយចោទលើម៉ែលក់ដីអោយគេ មិនអោយកូនដឹងគាត់តែប្រាប់ខ្ញុំ ទាល់តែខ្ញុំនិងប្រពន្ធខ្ញុំដែលជាម្ចាស់ដីបានអាចដេញគេចេញ ខ្ញុំនឹងប្រពន្ធទទួលបានដំណឹងនេះភ្លាម ក៏ ឡើងមកស្រុកភ្លាម ដើម្បីដោះស្រាយនៅសាលាឃុំអង្គរអង្គ ក៏ បានព្រមព្រៀងឯកភាពគ្នាសងលុយអោយ ឈ្មោះ [redacted] **ភីរះ** វិញ ដូចក្នុងកិច្ចសន្យាភ្ជាប់នៅជាមួយស្រាប់ ។

២៧២



Scanned with CamScanner

-ក្នុងឆ្នាំ ២០០៧ ឪពុកម្តាយមកស្រុកម្តងទៀតដើម្បី ធ្វើលិខិតផ្ទេរមរតកអោយទៅកូន ២ នាក់ គឺ

១-ឈ្មោះ [redacted] **ខឿន** ភេទ ស្រី

២-ឈ្មោះ [redacted] **ភ័ស** ភេទ ប្រុស

-ក្នុងចំណែកស្មើគ្នា។

ដោយឡែកកូនឯទៀតដែលគាត់មិនចែកឱ្យនោះព្រោះកូនទាំងនោះ ត្រូវបានរដ្ឋអំណាចចែករបរដី ស្មើៗគ្នាដូចឪពុក ម្តាយ ដែរ ។

**សំណូមពរ** សុំទាមទារដីបីកន្លែងតាមកិច្ចសន្យាផ្ទេរសិទ្ធិ ១៨.៧.២០០៧

**ការអះអាងរបស់សាក្សីដើមចោទ**

១-សាក្សីដើមចោទឈ្មោះ [redacted] **សុខ** បានឆ្លើយថា ខ្ញុំបាទធ្លាប់បានឃើញឈ្មោះ [redacted] **ឈួន** និង ប្រពន្ធឈ្មោះ [redacted] **ខេន** រស់នៅលើដីនេះតាំងពីឆ្នាំ ១៩៨៤ មកហើយឪពុកម្តាយរបស់ឈ្មោះ [redacted] **ខេន** បានស្លាប់នៅខេត្តកោះកុង ក្រៅពីនេះខ្ញុំបាទពុំបានដឹងអ្វីទៀតទេ ។

២-សាក្សីដើមចោទឈ្មោះ [redacted] **វ៉ាន** បានឆ្លើយថា ខ្ញុំបាទបានដឹងថាឈ្មោះ [redacted] **ឈួន** និង ប្រពន្ធ ឈ្មោះ [redacted] **ខេន** រស់នៅលើដីនេះជាយូរមកហើយ ។

៣-សាក្សីដើមចោទឈ្មោះ [redacted] **រឿង** បានឆ្លើយថា ខ្ញុំបាទបានឃើញឈ្មោះ [redacted] ឈួន និងប្រពន្ធឈ្មោះ [redacted] **ខេន** រស់នៅលើដីនេះជាយូរមកហើយ គឺ តាំងពីឆ្នាំ ១៩៨៤ មក ក្រោយមកការបែងចែកដីនេះឱ្យកូនណាមួយនោះរូបខ្ញុំមិនបានដឹងឡើយ ។

៤-សាក្សីដើមចោទឈ្មោះ [redacted] **សារី** បានឆ្លើយថាឈ្មោះ ញ៉ិក ឈួន បានកាន់កាប់ដីនេះតាំងពីឆ្នាំ ១៩៨៤ ខ្ញុំអត់បានដឹងថា ឪពុកម្តាយ [redacted] ខេន ផ្ទេរដីនេះអោយកូនណា ហើយនៅពេលណាទេ ក្នុងឆ្នាំ ១៩៨៤ ឈ្មោះ [redacted] ឈួន និង ប្រពន្ធនៅជាមួយឪពុកម្តាយហើយមិនបានឃើញចុងចំលើយនៅជាមួយទេ ។

**-ការអះអាងរបស់សាក្សីចុងចំលើយ**

១-សាក្សីចុងចំលើយឈ្មោះ [redacted] **ភ័ស** បានឆ្លើយថា នៅក្នុងឆ្នាំ ១៩៨៤ បងប្អូនរស់នៅជុំគ្នាក្នុងបន្ទុកឪពុកម្តាយទាំងអស់។ ក្នុងឆ្នាំ ១៩៨៥ ដល់ ឆ្នាំ ១៩៨៨ បង [redacted] **ឈួន** និង បង [redacted] **ខេន** បាននៅរស់នៅលើដីបត់ត្រង់ដែលរដ្ឋអំណាចបានចែក ។ របបដីដែលរដ្ឋអំណាច បានចែកឱ្យប [redacted] **ឈួន** និង ប្រពន្ធមានទំហំ ប្រហាក់ប្រហែលដីដែលរដ្ឋអំណាចចែកឱ្យ ឪពុកម្តាយដែរ ។ នៅក្នុងឆ្នាំ ១៩៨៨ បង [redacted] **ឈួន** បានលក់ដី ដែលរដ្ឋអំណាចចែកឱ្យទៅគេអស់ហើយ គាត់ក៏ឡើងមករស់នៅជាមួយឪពុកម្តាយវិញ ។ ដល់ឆ្នាំ ១៩៩៩ ឈ្មោះ [redacted] **សារ៉េត** បានមកចាក់ជើងសរសរបេតុងលើដីនេះប៉ុរុងធ្វើផ្ទះ ។ ដីទំនាស់នេះឪពុកម្តាយបានចែកឱ្យរូបខ្ញុំ និង បង [redacted] **សារ៉េត** ហើយខ្ញុំក៏បានលក់ចំណែកដីចំណែកខ្ញុំឱ្យទៅបង [redacted]

**សារ៉េត** ។ ឪពុកម្ដាយពិតជា បានផ្ទេរដីនេះឱ្យខ្ញុំពាក់កណ្ដាល ផ្ទេរឱ្យ [redacted] **សារ៉េត** ពាក់កណ្ដាល ហើយខ្ញុំបានផ្ទេរចំណែករបស់ខ្ញុំឱ្យបង [redacted] **សារ៉េត** ។

២-សាក្សីរបស់ចុងចំលើយឈ្មោះ [redacted] **សារ៉េត** បានឆ្លើយថា នៅឆ្នាំ ២០០៧ ឈ្មោះ [redacted] **ស៊ាន** និង ឈ្មោះ [redacted] **អ៊ុន** បានផ្ទេរដីទំនាស់នេះឱ្យទៅឈ្មោះ [redacted] **សុខឿន** និង ឈ្មោះ [redacted] **ភ័ស** ក្រោយមកឈ្មោះ [redacted] **ភ័ស** ក៏បានផ្ទេរដីចំណែករបស់ខ្លួនអោយទៅ ឈ្មោះ [redacted] **សារ៉េត** ហើយនៅថ្ងៃទី ៩.៨.២០១១ ឈ្មោះ [redacted] **ឈួន** ប្រពន្ធឈ្មោះ [redacted] **ខេន** បានព្រមព្រៀងទទួល យកដី ១០ ម ពីចុងចំលើយ ដោយមានលក្ខខណ្ឌហាម មិនឱ្យលក់បញ្ចាំ ផ្ទេរ ដេរដៀមដាមលើឈ្មោះ [redacted] **សារ៉េត** ប្រពន្ធឈ្មោះ [redacted] **ខឿន** បញ្ហាផ្ទះត្រូវរុះចេញ ពីដីរយៈពេល ២ ខែ ប៉ុន្តែក្រោយមកឈ្មោះ ញ៉ិក ឈួន មិនបានគោរពលក្ខខណ្ឌនេះទេ ។

៣-សាក្សីរបស់ចុងចំលើយឈ្មោះ [redacted] **ស៊ីន់** បានឆ្លើយថា ខ្ញុំបាទជាជំទប់ទី ២ ក្នុងឃុំអង្គរអង្គ ខ្ញុំសូមរៀបរាប់ការបែងចែកដី ក្រោយពីរបបប៉ុលពត គឺ រដ្ឋអំណាចបានចែកឱ្យអ្នកមានគ្រួសារ មានក្បាលដី ២០ ដូចៗគ្នា បណ្ដោយតាមជាក់ស្ដែង ហើយលោកតា [redacted] **ស៊ាន** ប្រពន្ធឈ្មោះ [redacted] **អ៊ុន** គាត់បានក្បាល ២០ ម ឯឈ្មោះ [redacted] **ឈួន** កាលនោះមានប្រពន្ធ ឈ្មោះ [redacted] **ខេន** រួចហើយដូចនេះ [redacted] **ឈួន** ក៏បានរបបស្មើនឹងពុកម្ដាយគាត់ដែរ ។ រីឯកូនៗដែលមិនទាន់មានគ្រួសារនៅក្នុងបន្ទុកឪពុកម្ដាយមិនបានទទួលរបប ២០ ម នេះទេ ។

-លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទបានធ្វើសេចក្ដីសន្និដ្ឋានថា : តាមការទាញហេតុផល ស្ដាប់ចំលើយសាក្សី និង ពិនិត្យលើភស្តុតាងកូនក្ដីរបស់ខ្លួន ឈ្មោះ [redacted] **ឈួន** បានមករស់ នៅលើដីទាំង ៤ កន្លែងតាំងពីឆ្នាំ ១៩៨៤ មកម្លេះ ហើយឆ្នាំ ២០០០ ឪពុកម្ដាយបានចាកចេញពីស្រុកទៅរស់នៅខេត្ត កោះកុង ដោយបានទុកដីនេះឱ្យកូនក្ដីខ្លួនជាអ្នកថែរក្សា កាន់កាប់ អាស្រ័យផលលើដីទាំង ៤ កន្លែងនេះ ទើបតែ ដល់ថ្ងៃ ៣០.៧.២០១២ ទើបចុងចំលើយមកទាមទារអះអាងថាជាដីរបស់ខ្លួន ។

-កូនក្ដីរបស់ខ្ញុំបានកាន់កាប់ដោយសុចរិត និង សន្តិវិធីអស់រយៈពេល ២៩ ឆ្នាំ ។

-ឪពុកម្ដាយឈ្មោះ [redacted] **ស៊ាន** និង [redacted] **អ៊ុន** បានចាកចេញនៅឆ្នាំ ២០០០ បានប្រគល់ដីទាំង ៤ កន្លែង មកអោយកូនក្ដីនាងខ្ញុំជាកម្មសិទ្ធិ ម្យ៉ាងទៀតពួកគាត់បោះបង់ការកាន់កាប់ដីទាំងនេះមុនច្បាប់ភូមិបាល ចូលជាធរមាន គឺ នៅមុនឆ្នាំ ២០០១ ។ នាងខ្ញុំសំណូមពរ សុំឱ្យកូនក្ដីខ្ញុំទទួលសិទ្ធ ជាម្ចាស់ចំនួនពាក់កណ្ដាលម្នាក់ជាមួយចុងចំលើយ ។

## សំអាងហេតុ

## យល់ឃើញថា

-ដើមចោទឈ្មោះ [redacted] **ឈួន** បានប្ដឹងទាមទារដី :



Scanned with CamScanner

35/6

-ទាមទារដីភូមិទំហំ ២០ ម គុណ ១០០ម

-ទាមទារដីចំការទំហំ ២០ ម គុណ ៣០០ ម

-ទាមទារដីស្រែប្រាំងទំហំ ២១ ម គុណ ២៧០ ម

-ទាមទារដីចំការទំហំ ២០ ម គុណ ៣០០ ម

ដោយសំអាងហេតុថា ខ្លួនបានរស់នៅ និង ធ្វើចំការ ធ្វើស្រែប្រាំងតាំងឆ្នាំ ១៩៨៤ មកម្លេះ រហូតមកដល់បច្ចុប្បន្ននេះក៏កំពុងកាន់កាប់ដីទាំងអស់នេះដែរ ដោយមានសាក្សី ១ ឈ្មោះ [redacted] **សុខ** ២-ឈ្មោះ [redacted] **ភឿង** ៣-ឈ្មោះ [redacted] **សារី** ៤- ឈ្មោះ [redacted] **វ៉ាន** ជាអ្នកដឹងលឺ ។

**<u>យល់ឃើញថា</u>**

-តាមសេចក្ដីថ្លែងការណ៍តបរបស់ចុងចំលើយឈ្មោះ [redacted] **សារ៉េត** ប្រពន្ធឈ្មោះ [redacted] **សុខឿន** ថា នៅឆ្នាំ ១៩៨៤ ពិតជារស់នៅលើដីនេះមែន ប៉ុន្តែរស់នៅជុំគ្នាជាមួយឳពុកម្ដាយ និង បងប្អូនទាំងអស់ដល់ ឆ្នាំ ១៩៨៦ ឈ្មោះ [redacted] **ឈួន** និង ប្រពន្ធឈ្មោះ [redacted] **ខេន** បាននៅរស់លើដីរបស់គាត់ឯបត់ត្រង់ដែលជាដីរបស់រដ្ឋអំណាចចែកអោយអស់រយះពេល ៣ ឆ្នាំ ក្រោយមកឈ្មោះ [redacted] **ឈួន** ក៏ លក់ដីរបស់គាត់ហើយមកសុំស្នាក់នៅលើដីភូមិរបស់ចុងចំលើយ ដែលចុងចំលើយទទួលបានពីឳពុកម្ដាយ កាលនោះចុងចំលើយយល់ថាជាបងប្អូន ក៏ អោយឈ្មោះ [redacted] **ឈួន** រស់នៅបណ្ដោះអាសន្ន ។

នៅថ្ងៃទី ១៨.៧.២០០៧ ឳពុកឈ្មោះ [redacted] **ហ៊ាន** និង ម្ដាយឈ្មោះ [redacted] **ន** បានផ្ទេរសិទ្ធិកាន់កាប់ដី បីកន្លែង មានដីប្រាំង ដីចំការ ដីភូមិ+ដីចំការ មកអោយកូន ០២ នាក់ ទី១ កូនឈ្មោះ [redacted] **ខឿន** ( ចុងចំលើយ ) ទី ២ កូនឈ្មោះ [redacted] **ភ័ស** តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដីចុះថ្ងៃទី ១៨.៧.២០០៧ ចំនួន ៣ ច្បាប់ ។

**-ទី ១** ដីប្រាំងមានទំហំ ១៩.៥០ ម គុណ ៤០០ ម មានព្រំប្រទល់

-ខាងកើតទល់ទឹក

-ខាងលិចទល់នឹងដីឈ្មោះ [redacted] **ហោ**

-ខាងជើងទល់ដីឈ្មោះ [redacted] **យ៉ាន់**

-ខាងត្បូងទល់ដីឈ្មោះ [redacted] **សាឯម**

**-ទី ២** ដីចំការ(ដីឡូត៍ ) មានទំហំ ៨ ម គុណ ៧០០ ម មានព្រំប្រទល់

-ខាងកើតទល់នឹងផ្លូវរទេះ

-ខាងលិចទល់នឹងផ្លូវរទេះ

-ខាងជើងទល់នឹងដីឈ្មោះ [redacted] **សន**

-ខាងត្បូងទល់ដីឈ្មោះ [redacted] **សាឯម**

35/5

**-ទី ៣** ដីភូមិ+ចំការមានទំហំ ២០ ម គុណ ៥០០ ម មានព្រំប្រទល់

-ខាងកើតទល់នឹងទន្លេ

-ខាងលិចទល់ដីប្រាំង

-ខាងជើងទល់ដីឈ្មោះ [redacted] **ថារី**

-ខាងត្បូងទល់ដីឈ្មោះ [redacted] **ហួយ**

-ដីទាំងបីកន្លែងខាងលើស្ថិតនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

-នៅថ្ងៃទី ០៩.១១.២០០៧ ឈ្មោះ [redacted] **ភ័ស** បានផ្ទេរសិទ្ធិកាន់កាប់ដីដែលជាចំណែករបស់ខ្លួន ដែលឪពុកម្តាយចែកអោយពាក់កណ្តាលជាមួយឈ្មោះ [redacted] **សុខឿន** អោយមកឈ្មោះ [redacted] **សារ៉េត** ប្រពន្ធឈ្មោះ [redacted] **សុខឿន** ចំនួនដីរបស់ [redacted] **ភ័ស** ទាំងបីកន្លែងខាងលើ ។

នៅថ្ងៃទី ១៣.៨.២០០៧ ចុងចំលើយឈ្មោះ [redacted] **សារ៉េត** បានធ្វើសំណើរសុំលិខិតកាន់កាប់ដីធ្លីមានដីភូមិ ទំហំ ២០០០ ម ការេ ដីចំការទំហំ ៨០០០ ម ដីប្រាំងទំហំ ៧៨០០ ម ដីចំការ (ដីឡូត៍) ទំហំ ៥៦០០ ម ដែលមានចុះហត្ថលេខាទទួលស្គាល់ដោយលោកមេភូមិ វាងរបងក្រោម ឈ្មោះ [redacted] **ស៊ាន** និង លោកមេឃុំអង្គរអង្គឈ្មោះ លោក [redacted] **ស៊ិន** ។

**<u>យល់ឃើញថា</u>**

ចុងចំលើយឈ្មោះ [redacted] **សារ៉េត** បានដាក់ភស្តុតាងឯកសារមានដូចខាងក្រោម :

១-លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] **ស៊ាន** អោយទៅឈ្មោះ [redacted] **ភ័ស** និង ឈ្មោះ [redacted] **ខឿន** ចំនួន ០៣ ច្បាប់ ។

២-លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] **ភ័ស** អោយទៅ ឈ្មោះ [redacted] **សារ៉េត** និង ឈ្មោះ [redacted] **ខឿន** ចំនួន ០៣ ច្បាប់ ។

៣-សំណើរស្នើសុំលិខិតកាន់កាប់ដីធ្លី ចុះថ្ងៃទី ១៣.៨.២០០៧ របស់ឈ្មោះ [redacted] **សារ៉េត** និង ឈ្មោះ [redacted] **ខឿន** ចំនួន ០៤ ច្បាប់ ។

៤-កំណត់ហេតុស្តីពីដំណោះដោះស្រាយដីធ្លីវាងដើមបណ្តឹង [redacted] **សារ៉េត** និង ចុងបណ្តឹង នៅ ខេន ចុះថ្ងៃទី ០៩.៨.២០១១ ចំនួន ០១ ច្បាប់ ។

៥-កិច្ចសន្យាចុះថ្ងៃទី ០៩.៨.២០១១ ចំនួន ០១ ច្បាប់ ។

៦-លក្ខ័ណព្រមព្រៀងរបស់ឈ្មោះ [redacted] **ខេន** និង ប្តីឈ្មោះ [redacted] **ឈួន** ចុះថ្ងៃទី ០៩.៨.២០១១ ចំនួន ០១ ច្បាប់ ។

៧-លិខិតប្រគល់ ចុះថ្ងៃទី ០៩.៨.២០១១ ចំនួន ០១ ច្បាប់ ។

២៧១



Scanned with CamScanner

៨-កិច្ចសន្យាជួលដី ចុះថ្ងៃទី ១៩.៧.២០០៧ ចំនួន ០១ ច្បាប់ ។

៩-លិខិតទិញ លក់ ចុះថ្ងៃទី ០១.៨.២០១២ ចំនួន ០១ ច្បាប់ ។

១០-គំនូសប្លង់កន្លែងដីទំនាស់ ចំនួន ០១ ច្បាប់ ។

១១-ពាក្យបណ្ដឹងចុះថ្ងៃទី ០២.៨.២០១២ ។

១២-របាយការណ៍សកម្មភាពចុះថ្ងៃទី ០៣.៨.២០១១ ។

១៣-សេចក្ដីជូនដំណឹងចុះថ្ងៃទី ១៩.៨.២០១១

១៤-ដីកាអមលេខ ០០៧ ចុះថ្ងៃទី ០២.៨.២០១២

១៥-បង្កាន់ដៃអង្កេតវាស់វែងដីធ្លី

**យល់ឃើញថា**

-តាមការពិនិត្យនៃការកាន់កាប់ដីទាំង ៤ កន្លែង គឺ មានការទទួលស្គាល់ថាបានរស់នៅរួមគ្នាជាមួយឪពុកម្ដាយមានន័យថា តា [redacted] **ស៊ាន** និង យាយ [redacted] **អ៊ុន** ជាមេគ្រួសារក្រោមដំបូលផ្ទះតែមួយ ។

-នៅឆ្នាំ ១៩៨០ រដ្ឋអំណាចមានគោលនយោបាលចែកដីឱ្យគ្រួសារណាដែលមានប្ដីប្រពន្ធហើយ គឺ ទទួលបានរបបដីរបស់រដ្ឋដូចដែលគ្រួសាររបស់ឈ្មោះ [redacted] **ឈួន** ប្រពន្ធឈ្មោះ [redacted] **ខេន** ទទួលបានរបបដីរបស់រដ្ឋចែកឱ្យដែរហើយ ។

-សំអាងលើស្ថានភាពនៃការកាន់កាប់ដូចដែលមានបង្កាន់ដៃដីធ្លី ចុះថ្ងៃទី ២៩.៣.១៩៩២ របស់ឈ្មោះ [redacted] **ស៊ាន** យាយ [redacted] **អ៊ុន** ពិតមែន ។ ដោយឡែកឈ្មោះ [redacted] **ឈួន** ប្រពន្ធឈ្មោះ [redacted] **ខេន** គឺ ពិតជាបានទទួល របបដី ដែលរដ្ឋបានចែកឱ្យមានទំហំ ២០ ម គុណ ២០០ម ដូច្នេះដើមចោទសិទ្ធិកាន់កាប់ដីនេះ ប៉ុន្តែមិនដឹងមូលហេតុអ្វីទើបដើមចោទលក់ដីនេះ ។

-ស្ថានភាពនៃការកាន់កាប់របស់ឈ្មោះ [redacted] **ឈួន** ប្រពន្ធឈ្មោះ [redacted] **ខេន** បានចូលទៅកាន់កាប់លើដីដែលមានម្ចាស់រួចទៅហើយគឺជាកម្មសិទ្ធិតា [redacted] **ស៊ាន** យាយ [redacted] **អ៊ុន** ។ ទោះបីតា **ស៊ាន** យាយ **អ៊ុន** ទៅរស់នៅខេត្តកោះកុង ឆ្នាំ ២០០០ ប៉ុន្តែយាយ **អ៊ុន** ឧស្សាហ៍មកមើលថែទាំដីរបស់គាត់ មិនមែនមានន័យថាតា **ស៊ាន** យាយ **អ៊ុន** បោះបង់ការកាន់កាប់ដីរបស់គាត់ឡើយ ។

-តា [redacted] **ស៊ាន** យាយ [redacted] **អ៊ុន** មានបង្កាន់ដៃដីរបស់គាត់ត្រឹមត្រូវគាត់ប្រគល់បង្កាន់ដៃដីរបស់គាត់ឱ្យទៅអ្នកណាមានន័យថា គាត់បញ្ឈប់ការកាន់កាប់ ហើយគាត់ប្រគល់ឱ្យអ្នកកាន់កាប់បន្ត ។



Scanned with CamScanner

**យល់ឃើញថា**

-ដីនេះជារបស់តា [redacted] **ស៊ាន** យាយ [redacted] **អ៊ិន** គាត់មានសិទ្ធិចាត់ចែងផ្ដាច់មុខរបស់គាត់ តុលាការមើលឃើញថា គាត់ចាត់ចែងប្រគល់ឱ្យទៅឈ្មោះ [redacted] **ខឿន** និង ឈ្មោះ [redacted] **ភ័ស** ការប្រគល់សិទ្ធិចាត់ចែងនេះមានលក្ខណៈត្រឹមត្រូវ ។

-ទាក់ទិននឹងឯកសារភស្តុតាងរបស់ដើមចោទចុះថ្ងៃទី ៩.០២.២០១៣ គឺ មេឃុំបានបញ្ជាក់ថា ឈ្មោះ [redacted] **ឈួន** បានសង់ផ្ទះលើដីតា **ស៊ាន** យាយ **អ៊ិន** ។

-ឯកសារមេប៉ុស្ដិ៍នគរបាលរដ្ឋបាលអង្គរអង្គចុះថ្ងៃទី ០២.៨.២០១២ បញ្ជាក់ថាឈ្មោះ [redacted] **សារ៉េត** មិនមានបញ្ជីស្នាក់នៅក្នុងភូមិនេះទេ លិខិតបញ្ជាក់នេះមិនមានពាក់ពន្ធ័នឹងការប្រគល់ទទួលដីដែលឪពុកម្ដាយចែកឱ្យនោះទេ ។

-ចុងចំលើយបានផ្ដល់ឯកសារ

-លិខិតផ្ទេរសិទ្ធិរបស់ឪពុកម្ដាយ

-លិខិតផ្ទេរសិទ្ធិរបស់ឈ្មោះ [redacted] **ភស័**

ដូច្នេះតុលាការអាចពិចារណាបាន

**យល់ឃើញថា**

-តាមការស្ដាប់ចំលើយសាក្សីដើមចោទទាំង ៤ នាក់ បានឆ្លើយប្រហាក់ប្រហែលគ្នាថា បានឃើញដើមចោទកាន់កាប់លើដីនេះប៉ុន្តែមិនបានដឹងពីស្ថានភាពនៃការចាត់ចែងរបស់តា [redacted] **ស៊ាន** យាយ [redacted] **អ៊ិន** នោះឡើយ ។

-តាមការស្ដាប់របស់សាក្សីចុងចំលើយឈ្មោះ [redacted] **ភ័ស** នៅឆ្នាំ ១៩៨៤ បងប្អូនរស់នៅជុំគ្នាក្នុងបន្ទុកឪពុកម្ដាយឆ្នាំ ១៩៨៦ ឈ្មោះ [redacted] **ឈួន** នៅរស់នៅដីដែលរដ្ឋចែកអោយដល់ឆ្នាំ ១៩៨៨ ដើមចោទមករស់នៅលើដីនេះវិញ ។ ឈ្មោះ [redacted] **ភ័ស** ពិតជាបានប្រគល់ដីរបស់ខ្លួនឱ្យទៅឈ្មោះ [redacted] **ខឿន** ។

-តាមចំលើយសាក្សីឈ្មោះ [redacted] **សារ៉េត** បានដឹងពីសារបានទំនាស់នេះរបហូតបានប្រើប្រាស់គោលការព្រមព្រៀងដើមចោទយល់ព្រមខ្ចីដីចុងចំលើយ ១០ ម រស់នៅបណ្ដោះអាសន្ន និង មានលក្ខខណ្ឌ ពេលនោះដើមចោទបានទទួលយល់ព្រម ប៉ុន្តែ ដើមចោទមិនមានភាពសុចចរិត មានការកែប្រែមិនយកចំនួន ១០ ម ហើយមកប្ដឹងទាមទារយកដីទាំងអស់ទៅវិញ ។

-តាមចំលើយសាក្សីឈ្មោះ [redacted] **ស៊ន់** បានដឹងថាដើមចោទបានទទួលរបបដីរដ្ឋចំនួន ២០ ម គុណ ២០០ម រួចហើយ រីឯកូនៗដែលមិនទាន់មានគ្រួសារមិនទាន់បានទទួលរបបដីនេះទេ ។

35/2

**យល់ឃើញថា**

សេចក្ដីសន្និដ្ឋានរបស់លោកស្រីមេធាវីតំណាងដោយអាណត្តិអោយដើមចោទ បានលើកហេតុផលការពារអោយកូនក្ដីរបស់ខ្លួននេះតុលាការមិនអាចទទួលយកបានឡើយ ។

**យល់ឃើញថា**

ប្រាក់ប្រដាប់ក្ដីគប្បីឱ្យដើមចោទជាអ្នកទទួល

**សេចក្ដីសម្រេចបញ្ចប់**

១-**ច្រានចោល** ការទាមទារចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] **ឈួន** ប្រពន្ធឈ្មោះ [redacted] **ខេន** ចាប់ពីសាលក្រមចូលជាស្ថាពរតទៅ ។

២-**ប្រគល់ដី** ដូចខាងក្រោម :

**-ទី ១** ដីប្រាំងមានទំហំ ១៩.៥០ ម គុណ ៤០០ ម មានព្រំប្រទល់

-ខាងកើតទល់ទទឹក

-ខាងលិចទល់នឹងដីឈ្មោះ [redacted] **ឃោ**

-ខាងជើងទល់ដីឈ្មោះ [redacted] **យ៉ាន់**

-ខាងត្បូងទល់ដីឈ្មោះ [redacted] **សាឯម**

**-ទី ២** ដីចំការ( ដីឡូត៍ ) មានទំហំ ៨ ម គុណ ៧០០ ម មានព្រំប្រទល់

-ខាងកើតទល់នឹងផ្លូវរទេះ

-ខាងលិចទល់នឹងផ្លូវរទេះ

-ខាងជើងទល់នឹងដីឈ្មោះ [redacted] **សន**

-ខាងត្បូងទល់ដីឈ្មោះ [redacted] **សាឯម**

**-ទី ៣** ដីភូមិ+ចំការមានទំហំ ២០ ម គុណ ៥០០ ម មានព្រំប្រទល់

-ខាងកើតទល់នឹងទន្លេ

-ខាងលិចទល់ដីប្រាំង

-ខាងជើងទល់ដីឈ្មោះ [redacted] **ថាវី**

-ខាងត្បូងទល់ដីឈ្មោះ [redacted] **ហួយ**

ដីទាំងបីកន្លែងស្ថិតនៅភូមិ វាលរបងក្រោម ឃុំ អង្គរអង្គ ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

អោយទៅចុងចំលើយឈ្មោះ [redacted] **សាវ៉េត** ប្រពន្ធឈ្មោះ [redacted] **សុខឿន** ចាប់ពីសាលក្រមចូលស្ថាពរតទៅ ។

២៧៩



Scanned with CamScanner

៣-ប្រាក់ប្រដាប់ក្ដីអោយដើមចោទជាអ្នកទទួល។

-សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ចំពោះមុខគូភាគី មេធាវីតំណាងដោយអាណត្តិអោយដើមចោទ សំរេចនៅថ្ងៃទី ២០ ខែ កុម្ភះ ឆ្នាំ ២០១៣ បើកសិទ្ធិអោយប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ចៅក្រមជំនុំជម្រះ

[redacted]